# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ១៩៩៧ ក.ក.ប./

*រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥*

## ប្រកាស
## ស្តីពី
## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០០៦

## រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញ សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញអនុក្រឹត្យ លេខ ១២១ អនក្រ/បក. ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០០៥ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០០៦

## ស ម្រេ ច

**ប្រការ១.-** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅ ឆ្នាំ២០០៦ ដោយត្រូវអនុញ្ញាតឱ្យកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ទាំងអស់ដែលមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារដោយមានប្រាក់ឈ្នួល តាមការកំណត់ដូចតទៅ:

-បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី០២ ខែ មករា ជំនួសថ្ងៃទី ០១ ខែ មករា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា

-បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១៣ ខែ កុម្ភៈ

-បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា

-បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី១៤ ,១៥ និងថ្ងៃទី ១៧ ខែ មេសា ជំនួសថ្ងៃទី ១៦ ខែ មេសា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែ ឧសភា

-បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១២ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនបីថ្ងៃ គឺថ្ងៃទី១៣ ១៥ និងថ្ងៃទី ១៦ ខែ ឧសភា ជំនួសថ្ងៃទី ១៤ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ១៧ ខែ ឧសភា ជំនួសថ្ងៃទី ១៦ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា **នរោត្តមមុនីនាថ សីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ១៩ ខែ មិថុនា ជំនួសថ្ងៃទី ១៨ ខែ មិថុនា ដែលចំថ្ងៃអាទិត្យ

-បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ២១ ២២ និងថ្ងៃទី ២៣ ខែ កញ្ញា

-បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃ គឺថ្ងៃទី ២៥ ខែ កញ្ញា ជំនួសថ្ងៃទី ២៤ ខែ កញ្ញា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចបរមនាថ **នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣០ ខែ តុលា ជំនួសថ្ងៃទី ២៩ ខែ តុលា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះវររាជបិតា ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុ** ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣១ ខែ តុលា

-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ចំនួនបីថ្ងៃ គឺថ្ងៃទី ០៤ ០៦ និងថ្ងៃទី០៧ ខែ វិច្ឆិកា ជំនួសថ្ងៃទី ០៥ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ

-បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា

-បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិ ចំនួនមួយថ្ងៃ គឺថ្ងៃទី ១១ ខែ ធ្នូ ជំនួសថ្ងៃទី ១០ ខែ ធ្នូ ដែលចំថ្ងៃអាទិត្យ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា មាត្រា១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករនិយោជិត ទាំងអស់ ។

**ប្រការ៣.-** ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ៣៣៣ ក.ក.ប.វ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ញៀប_ប៊ុនជិន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ ដើម្បីជូនជ្រាប
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ដើម្បីផ្សព្វផ្សាយ និងអនុវត្ត
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត ដើម្បីជ្រាប និងអនុវត្ត
- កាលប្បវត្តិ និងឯកសារ